

**ក្រសួងការពារជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃអង្គារ ៩កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១៧

# សារជូនពរ

## សូមគោរពជូន

## សម្ដេចអគ្គមហាសេនាបតីតេជោ... 

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំសកល២០១៨**

**សម្ដេចវិបុលសេនាភក្ដី និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្ដីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល ២០១៨ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្ដេចវិបុលសេនាភក្ដី** និង**លោកជំទាវ** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវលទ្ធផលត្រចះត្រចង់ថ្មីៗថែមទៀត។

ក្នុងទិវាដ៏ថ្លៃថ្លានេះយើងខ្ញុំទាំងអស់គ្នា តែងតែនឹកឃើញនិងចងចាំជានិច្ចមិនអាចបំភ្លេចបានចំពោះ សកម្មភាពស្នេហាជាតិប្រកបដោយគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចវិបុលសេនាភក្ដី** ដែលតែងតែបាន យកអស់កម្លាំងកាយចិត្ត និងរាល់បទពិសោធន៍មកបំរើផលប្រយោជន៍ជូនជាតិមាតុភូមិនិងប្រជាជន។ ជាក់ស្ដែងរយៈពេលកន្លងមក **សម្ដេចវិបុលសេនាភក្ដី** បានខិតខំចូលរួមនឹងដឹកនាំស្ថាប័នព្រឹទ្ធសភា ឱ្យក្លាយជាអង្គនីតិប្បញ្ញត្តិមួយប្រកបដោយសក្ដានុពលភាព ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋមួយដែលជាមូលដ្ឋានគ្រឹះ ធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿង ស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងលើកកម្ពស់កិត្យានុភាពជាតិទាំងក្នុងតំបន់និងលើសកលលោក។

ជាថ្មីម្ដងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងអស់ ក្នុងនាមខ្ញុំ និងភរិយា សូមលើកហត្ថប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្ដេចវិបុលសេនាភក្ដី** និង **លោកជំទាវ** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី**ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវ** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**